**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

* * * * *

ក្រសួងសុខាភិបាល

មន្ទីរពេទ្យកាល់ម៉ែត

## កិច្ចសន្យា

រវាងមន្ទីរពេទ្យកាល់ម៉ែត និង ក្រុមហ៊ុនធានារ៉ាប់រង FORTE

អាស័យដ្ឋានលេខ 325 មហាវិថីម៉ៅសេទុង ភ្នំពេញ ស្តីពីការព្យាបាលជំងឺសំរាកពេទ្យផ្នែកជំងឺទូទៅ

និង សំរាកពេទ្យផ្នែកជំងឺវះកាត់

ភាគីទាំងសងខាងបានព្រមព្រៀងគ្នាដូចតទៅ :

ប្រការ 1: មន្ទីរពេទ្យជាអង្គភាពព្យាបាលអ្នកជំងឺ ស្ថិតនៅទីតាំង លេខ 3 មហាវិថីព្រះមុនីវង្ស តំណាងដោយ លោក សាស្ត្រាចារ្យ ហេង តៃគ្រី នាយកមន្ទីរពេទ្យ ជាភាគី "ក" ។

ប្រការ 2: ក្រុមហ៊ុនធានារ៉ាប់រង FORTE ទីតាំងលេខ 325 មហាវិថីម៉ៅសេទុង ភ្នំពេញ តំណាងដោយលោក CHARLES CHEO នាយកគ្រប់គ្រង ជាភាគី "ខ" ។

ប្រការ 3: មន្ទីរពេទ្យកាល់ម៉ែត មានភារកិច្ចព្យាបាល ជំងឺផ្នែកជំងឺទូទៅ និង ជំងឺវះកាត់នូវ អតិថិជនរបស់ ក្រុមហ៊ុនធានារ៉ាប់រង FORTE ដែលចូលព្យាបាលនៅមន្ទីរពេទ្យ ។

ប្រការ 4: គ្រប់អ្នកជំងឺជាប់កិច្ចសន្យារបស់ក្រុមហ៊ុនធានារ៉ាប់រង FORTE ដែលត្រូវបញ្ជូនមកកាន់ មន្ទីរពេទ្យ ត្រូវមានចាំបាច់នូវលិខិតបញ្ជូនអ្នកជំងឺរបស់ក្រុមហ៊ុនផ្តល់អោយអ្នកជំងឺ ដើម្បីបង្ហាញដល់មន្ត្រីមន្ទីរពេទ្យ ប្រចាំការ ធ្វើការ 24 ម៉ោង ដោយបញ្ជាក់ឈ្មោះអ្នកជំងឺ ភេទ អាយុ សង្កាត់ ស្រុក ខេត្ត ។

ប្រការ 5: ក្នុងករណីជាប្រភេទជំងឺបន្ទាន់ដែលគ្មានលិខិតបញ្ជូនពីភាគី "ខ" ភាគី "ក" មានភារកិច្ចទទួលជំងឺជាបន្ទាន់ មុននឹង រាយការណ៍ទៅក្រុមហ៊ុនតាមក្រោយ យ៉ាងយូរ 24 ម៉ោង ។

ប្រការ 6: តារាងតំលៃរបស់ភាគី "ក" គិតជូនទៅភាគី "ខ" ត្រូវអនុវត្តតាមតារាងតំលៃរបស់ មន្ទីរពេទ្យកាល់ម៉ែត ដែលបានសំរេចអោយ ប្រើប្រាស់ជាផ្លូវការរបស់ ក្រុមប្រឹក្សាភិបាលប្រចាំមន្ទីរពេទ្យ ។

ប្រការ 7: អ្នកជំងឺរបស់ភាគី "ខ" ដែលសំរាក ពេទ្យចំពោះក្នុង ការព្យាបាល ត្រូវបានកំណត់ក្រោម 500US$ (ប្រាំរយដុល្លាអាមេរិក) ជំងឺម្នាក់ ។ ក្នុងករណីលើសពី 500US$ ភាគី "ក" ត្រូវរាយការបន្ទាន់ ជាលាយលក្ខណ៍អក្សរ ឬ មួយ តាមទូរស័ព្ទ អោយដំណឹងទៅភាគី "ខ" ជាបន្ទាន់ភ្លាម ដើម្បីសុំការឯកភាពពីភាគី "ខ" ។

ប្រការ 8: ក្នុងការទូទាត់ប្រាក់ភាគី "ក" ចេញវិក្កយបត្រនៅរៀងរាល់ចុងខែនិមួយៗ ផ្ញើជូនទៅភាគី "ខ" ដោយភ្ជាប់ទៅជាមួយនូវសាលាកបត្រវេជ្ជសាស្ត្រ លំអិតស្តីពីការចំណាយ និង ឯកសារផ្សេងទៀត ដែលអាចទទួលស្គាល់ បានជាត្រឹមត្រូវ ដើម្បីធ្វើការទូទាត់ ។ ការទូទាត់កំណត់ពេលយ៉ាងយូរ 30 ថ្ងៃ ក្រោយពេលទទួលបាន វិក្កយបត្រពីភាគី "ក" ។

ប្រការ ៩: កិច្ចសន្យានេះ មានប្រសិទ្ធិភាព ចាប់ពីពេលចុះហត្ថលេខាព្រមព្រៀងអនុវត្តន៍ កិច្ចសន្យានេះត្រូវបាន បញ្ចប់ក្រោយរយៈពេល ៣០ថ្ងៃ បន្ទាប់ពីភាគីណាមួយក្នុងចំណោមភាគី ទាំងពីរជូនដំណឹងស្តីពីការបញ្ចប់ នៃកិច្ចសន្យានេះ ។

ធ្វើជាបីច្បាប់:

- វក្សាទុកភាគី "ក" ១ ច្បាប់
- វក្សាទុកភាគី "ខ" ១ ច្បាប់
- វក្សាទុកការិយាល័យគណនេយ្យ ១ ច្បាប់

ភ្នំពេញ ថ្ងៃទី...4...ខែ...7...ឆ្នាំ 2000

ភាគី "ខ"
នាយកគ្រប់គ្រងក្រុមហ៊ុន

ភាគី "ខ"
នាយកមន្ទីរពេទ្យ

វេជ្ជបណ្ឌិត ហេង តៃគ្រី